# រឿងទី៤៖ ម៉ូសេ១ (ទារកតូចម៉ូសេ)

**ខគម្ពីរ៖ និក្ខមនំ ២៖១០**

ព្រះនាងដាក់ឈ្មោះថា «ម៉ូសេ» ដោយមានសវនីយ៍ថា៖ «ខ្ញុំបានស្រង់កូននេះចេញពីទឹកមក»។

ជនជាតិអ៊ីស្រាអែល បានរស់នៅក្នុងស្រុកអេស៊ីបអស់រយៈពេលជាងបួនរយឆ្នាំ។
ដោយព្រះគុណព្រះជាម្ចាស់ ជនជាតិអ៊ីស្រាអែលបានង្កើតកូនជាច្រើនពេញស្រុកអេស៊ីប។
ប៉ុន្តែស្ដេចផារ៉ោនមានការព្រួយបារម្ភជាខ្លាំងព្រោះកូនចៅជនជាតិអ៊ីស្រាអែលកាន់តែច្រើនឡើងបែបនេះ។
ដូច្នេះ ស្ដេចផារ៉ោន បានធ្វើទុក្ខទោសដល់ជនជាតិអ៊ីស្រាអែលជាខ្លាំងដោយឱ្យពួកគេធ្វើជាទាសករ វាយធ្វើបាប យ៉ាងព្រៃផ្សៃ។
ប៉ុន្តែ ជនជាតិអេស៊ីបកាន់តែធ្វើបាបជនជាតិអ៊ីស្រាអែល ជនជាតិអ៊ីស្រាអែលកាន់តែមានចំនួនច្រើនទៅៗ ដោយព្រះគុណព្រះជាម្ចាស់។
មានថ្ងៃមួយ ស្ដេចផារ៉ោន បានកោះហៅពួកឆ្មបទាំងអស់ឱ្យមកជួប។ ឆ្មបគឺជាអ្នកជួយសម្រាលកូន។
ស្ដេចផារ៉ោនបានប្រាប់ទៅពួកឆ្មបដែលជួយសម្រាលកូនឱ្យពួកស្រីៗសាសន៍អ៊ីស្រាអែលថាបើគេសម្រាលបានកូនស្រីនោះចូរទុកឱ្យនៅរស់ចុះ
ប៉ុន្តែបើសម្រាលបានកូនប្រុសវិញ ត្រូវបោះចូលទៅទន្លេនីលសម្លាប់ចោលទៅ។
ប៉ុន្តែពួកឆ្មបទាំងនោះ ជាអ្នកកោតខ្លាចព្រះជាម្ចាស់ ក៏បានជួយកូនប្រុសៗឱ្យនៅរស់វិញ។
ព្រះជាម្ចាស់បានប្រទានពរដល់ពួកឆ្មបទាំងនោះ។



ព្រះជាម្ចាស់បានស្ដាប់ការអធិស្ឋាន និងការទទូចអង្វររបស់ពួករាស្ត្រអ៊ីស្រាអែល ទ្រង់ក៏បានជួយសង្គ្រោះពួកគេ។
មានថ្ងៃមួយ មានស្ត្រីសាសន៍អ៊ីស្រាអែលម្នាក់រស់នៅក្នុងស្រុកអេស៊ីបបានបង្កើតកូនប្រុសម្នាក់។
ដោយកូនប្រុសដែលទើបនិងកើតនោះមានរូបស្រស់ល្អនិងគួរឱ្យស្រឡាញ់ពេក ទើបស្ត្រីនោះមិនដាច់ចិត្តបោះកូន ទៅក្នុងទន្លេនីលទេ។
ដូច្នេះ ក៏សម្រេចលាក់ទុកចិញ្ចឹមបានបីខែ។
ប៉ុន្តែ ដោយសម្លេងយំរបស់កូនតូចនោះតែខ្លាំងឡើងៗដូច្នេះ ធ្វើឱ្យម្ដាយមិនអាចចិញ្ចឹមកូននោះបានទៀតទេ។
ម្ដាយរបស់កូនតូចនោះ បានអធិស្ឋានទាំងទួញយំទូលទៅព្រះជាម្ចាស់។
ទីបំផុត ស្ត្រីក៏យកកន្ត្រកធ្វើពីដើមបបុស មកពរជ័រលាបម្រ័ក្សណ៍ដើម្បីកុំឱ្យលេច រួចដាក់កូនតូចក្នុងកន្ត្រកនោះ។
ហើយបន្ទាប់មក នាងក៏យកកន្ត្រកដែលបានដាក់កូននោះទៅបណ្ដែតនៅក្នុងទន្លេនីល។



ម៉ារាមជាបងស្រីរបស់កូនតូចនោះក៏លាក់ខ្លួនតាមគុម្ពព្រៃងតាមមើលប្អូនពីចម្ងាយរហូត។

កន្ត្រកដែលមានកូនតូចនៅក្នុងនោះបានអណ្តែតរសាត់តាមទឹក រហូតទៅដល់កន្លែងបុត្រីស្តេចផារ៉ោនស្រង់ទឹក។

ព្រះនាង បានឃើញកន្ត្រកដែលអណ្តែតមកជាប់នឹងគុម្ពព្រៃង។ ភ្លាមនោះ ម៉ារាមដែលកំពុងលាក់ខ្លួនក៏រត់មករកព្រះនាង។

ម៉ារាមក៏បានសួរទៅព្រះនាងថាចង់រកមនុស្សមកមើលថែកូនតូចនោះដែរទេ។

ព្រះនាងក៏ឆ្លើយទៅនាងថាកំពុងស្វែងរកអ្នកមើលថែកូនតូចនោះ។

ម៉ារាម សប្បាយចិត្តជាខ្លាំងក៏ប្រញាប់រត់ទៅផ្ទះវិញយ៉ាងលឿន។

នាងបាននិយាយប្រាប់ទៅម្តាយនាង។ ម្តាយកូនតូចនោះក៏ប្រញាប់រត់ទៅជួបព្រះនាង។

ព្រះជាម្ចាស់បានឱ្យកូនតូចនោះរស់នៅជាមួយម្តាយរហូតដល់ធំពេញវ័យ។

ព្រះនាងបានដាក់ឈ្មោះឱ្យកូនតូចនោះថា«ម៉ូសេ»។ ម៉ូសេ គឺមានន័យថា ស្រង់ចេញពីទឹក។ ពីមួយថ្ងៃទៅមួយថ្ងៃ ម៉ូសេកាន់តែធំទៅៗ។

ម្តាយបង្កើតម៉ូសេបានអប់រំប្រៀនប្រដៅម៉ូសេឱ្យមានជំនឿបម្រើព្រះជាម្ចាស់។

ម៉ូសេបានក្លាយជាបុត្រារបស់ព្រះនាង ហើយទទួលបានការអប់រំជាច្រើននៅក្នុងវាំងជាមួយនឹងបុត្រាៗផ្សេងទៀត។

ជាច្រើនឆ្នាំកន្លងទៅ ព្រះជាម្ចាស់បានធ្វើឱ្យម៉ូសេក្លាយជាអ្នកដឹកនាំដ៏អស្ចារ្យដឹកនាំជនជាតិអ៊ីស្រាអែល។

ម៉ូសេបានធ្វើតាមព្រះបន្ទូលព្រះជាម្ចាស់ ដឹកនាំជនជាតិអ៊ីស្រាអែលដែលរងទុក្ខក្នុងស្រុកអេស៊ីប ឱ្យត្រឡប់ទៅ ស្រុកកំណើតវិញ។

ពេលនេះ ជនជាតិអ៊ីស្រាអែលទាំងអស់ថ្វាយបង្គំព្រះជាម្ចាស់យ៉ាងខ្ជាប់ខ្ជួន និងបានក្លាយជារាស្ត្រដ៏មានសេរីភាព របស់ព្រះជាម្ចាស់ ។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (និក្ខមនំ ២៖១០)

នាងដាក់ឈ្មោះថា «ម៉ូសេ» ដោយមានសវនីយ៍ថា៖
«ខ្ញុំបានស្រង់កូននេះចេញពីទឹកមក»



**សកម្មភាពទី១** សូមបិទបំណែកក្រដាសពណ៌ ដើម្បីតុបតែងកន្ត្រក។ (សម្ភារៈ៖ ខ្មៅដៃពណ៌, ក្រដាសពណ៌, កន្ត្រៃ, កាវ)



**សកម្មភាពទី២** សូមគិតអំពីខ្លឹមសារមេរៀនដែលរៀនបាននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

